ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់
កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ
**(MAFF-NIO for Rice-SDP)**

លេខ: ....០៥៨.... កពស/រប

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ**: របាយការណ៍ស្តីពីសកម្មភាព និងលទ្ធផលការងារប្រចាំត្រីមាសទី១ ឆ្នាំ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមរាយការណ៍ជូនឯកឧត្តមរដ្ឋមន្ត្រីអំពីសកម្មភាព និងលទ្ធផលការងារ នៃការអនុវត្តកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ ប្រចាំត្រីមាសទី១ ដែលមានដូចខាងក្រោមនេះ៖

## I)- ការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ និងលទ្ធកម្ម

### ១)- ការងាររដ្ឋបាល

១.១- ស្ថានភាពថ្នាក់ដឹកនាំ និងបុគ្គលិក MAFF-NIO

អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (MAFF-NIO) មានមន្ត្រីបម្រើការសរុបចំនួន១៥រូប ដែលក្នុងនោះមាន៖ នាយកគម្រោងចំនួន០១រូប នាយករងគម្រោងចំនួន០១រូប ប្រធានសម្របសម្រួលកម្មវិធីគម្រោងចំនួន០១រូប ប្រធានផ្នែករដ្ឋបាល គណនេយ្យនិងហិរញ្ញវត្ថុចំនួន០១រូប ប្រធានផ្នែកផែនការ និងអនុវត្តគម្រោងចំនួន០១រូប មន្ត្រីរដ្ឋបាលចំនួន០១រូប មន្ត្រីបច្ចេកទេសចំនួន០៤រូប មន្ត្រីស្ម័គ្រចិត្តចំនួន០២រូប អ្នកអនាម័យចំនួន០១រូប និងអ្នកបើកបរចំនួន០១រូប។ នៅក្នុងត្រីមាសនេះ មានមន្ត្រីបច្ចេកទេសចំនួន០២រូប បានសុំលាឈប់ពីគម្រោង ក្នុងនោះរួមមាន៖ លោក **ពេជ្រ រម្យនា** មន្ត្រីទទួលបន្ទុកគ្រប់គ្រងកិច្ចសន្យា និងកញ្ញា **ជា ពិសី** មន្ត្រីទទួលបន្ទុកយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ។

អង្គភាព MAFF-NIO បាន និងកំពុងដំណើរការឯកសារស្នើសុំកែសម្រួលសមាសភាព និងជ្រើសរើសមន្ត្រីបន្ថែមចំនួន០៤រូប ក្នុងនោះរួមមាន៖ មន្ត្រីទទួលបន្ទុកយេនឌ័រ និងបម្រែបម្រួលអាកាសធាតុ មន្ត្រីទទួលបន្ទុកគ្រប់គ្រងកិច្ចសន្យា មន្ត្រីទទួលបន្ទុកត្រួតពិនិត្យ និងវាយតម្លៃគម្រោង និងមន្ត្រីរដ្ឋបាល។

១.២- ទីប្រឹក្សាថ្នាក់ជាតិ

អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (MAFF-NIO) មានអ្នកជំនាញការផ្នែកគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុចំនួន០១រូប។

១.៣- សកម្មភាពរបស់បុគ្គលិក និងទីប្រឹក្សា

**+ វត្តមាននៅអង្គភាព MAFF-NIO**

វត្តមានរបស់មន្ត្រីមកបម្រើការងារនៅអង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (MAFF-NIO) មានដូចក្នុងបញ្ជីវត្តមានជូនភ្ជាប់។

**+ កិច្ចប្រជុំការងារផ្សេងៗនៅអង្គភាព MAFF-NIO:**

នៅក្នុងត្រីមាសទី១នេះ អង្គភាពអនុវត្តន៍គម្រោងថ្នាក់ជាតិសម្រាប់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (MAFF-NIO) បានអនុវត្តកិច្ចប្រជុំផ្សេងៗចំនួន១៤លើក។

**+ កិច្ចប្រជុំ/សិក្ខាសាលានៅថ្នាក់ខេត្តដែលរៀបចំដោយអង្គភាព MAFF-NIO:**

អង្គភាព MAFF-NIO បានរៀបចំកិច្ចប្រជុំ/សិក្ខាសាលានៅថ្នាក់ខេត្តចំនួន០១វគ្គ គឺ៖

- ថ្ងៃទី០១ ដល់ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៦: បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការកៀរពង្រាបដីដោយប្រព័ន្ធឡាហ្សែរ នៅខេត្តកំពង់ធំ។

**+ ការចូលរួមប្រជុំ/សិក្ខាសាលា/វគ្គបណ្តុះបណ្តាលនៅថ្នាក់កណ្តាលរបស់មន្ត្រីអង្គភាព MAFF-NIO:**

មន្ត្រីនៃអង្គភាព MAFF-NIO បានចូលរួមកិច្ចប្រជុំផ្សេងៗដែលរៀបចំឡើងដោយអង្គភាព គ្រប់គ្រង និងសម្របសម្រួលការអនុវត្តកម្មវិធី (PMO) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) រួមមាន៖

- ថ្ងៃទី១២ និង ១៣ ខែមករា ឆ្នាំ២០១៦: បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់គេហទំព័ររបស់កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ នៅឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)
- ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦: បានចូលរួមកិច្ចប្រជុំបើក (Kick-Off Meeting) ជាមួយមន្ត្រី PMO, NIOs, PIOs និង PIC ដើម្បីពិនិត្យលើផែនការសកម្មភាពរបស់អង្គភាពនីមួយៗ នៅឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)
- ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦: បានចូលរួមកិច្ចប្រជុំបូកសរុប (Wrap-Up Meeting) លទ្ធផលនៃការពិនិត្យលើផែនការសកម្មភាពរបស់អង្គភាពអនុវត្តន៍កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ នៅឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ (SNEC)
- ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦: បានចូលរួមប្រជុំអំពីការងារត្រួតពិនិត្យ និងវាយតម្លៃគម្រោង នៅទីស្នាក់ការធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។

**+ ការចូលរួមប្រជុំ/សិក្ខាសាលា/វគ្គបណ្តុះបណ្តាលនៅថ្នាក់ខេត្តរបស់មន្ត្រីអង្គភាព MAFF-NIO:**

មន្ត្រីនៃអង្គភាព MAFF-NIO បានចូលរួមវគ្គបណ្តុះបណ្តាលចំនួន០១លើក គឺ៖

- ថ្ងៃទី១៥ ដល់ ១៦ ខែមីនា ឆ្នាំ២០១៦: បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធត្រួតពិនិត្យការអនុវត្តគម្រោង នៅខេត្តបាត់ដំបង។

**+ ការចុះបំពេញបេសកកម្មទៅថ្នាក់ក្រោមជាតិ**

មន្ត្រីនៃអង្គភាព MAFF-NIO បានចុះបំពេញបេសកកម្មទៅកាន់ខេត្តគោលដៅអនុវត្តគម្រោង ដូចខាងក្រោម៖